# ធនាគារ ព្រីនស៍ ម.ក
# បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់សម្រាប់គណនីបញ្ញើមានកាលកំណត់

បញ្ញត្តិនិងលក្ខខណ្ឌនេះ ("**បញ្ញត្តិនិងលក្ខខណ្ឌ**") ត្រូវអនុវត្តលើគណនីបញ្ញើមានកាលកំណត់ទាំងអស់ ដែល ធនាគារ ព្រីនស៍ បានដាក់ឱ្យអតិថិជនប្រើប្រាស់ ("**គណនីបញ្ញើមានកាលកំណត់**")។ លោកអ្នក ត្រូវយកចិត្តទុកដាក់អាន និងយល់ឱ្យច្បាស់ អំពីបញ្ញត្តិនិងលក្ខខណ្ឌនេះ មុនពេលធ្វើការស្នើសុំបើកគណនីបញ្ញើមានកាលកំណត់ និងប្រើប្រាស់សេវាកម្មដែលពាក់ព័ន្ធជាមួយធនាគារយើង។ បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវអនុវត្តទន្ទឹមគ្នាជាមួយនឹងបញ្ញត្តិនិងលក្ខខណ្ឌទូទៅដែលគ្រប់គ្រងលើ គណនី សេវាកម្ម និងផលិតផល ("**បញ្ញត្តិនិងលក្ខខណ្ឌទូទៅ**") បញ្ញត្តិ និងលក្ខខណ្ឌគ្រប់គ្រងសេវាធនាគារឌីជីថល និងបញ្ញត្តិ និងលក្ខខណ្ឌពាក់ព័ន្ធដទៃទៀត ហើយ បញ្ញត្តិ និងលក្ខខណ្ឌនេះ ត្រូវមានឧត្តមានុភាព ក្នុងករណីមានភាពមិនស៊ីសង្វាក់គ្នារវាងបញ្ញត្តិនិងលក្ខខណ្ឌនេះ និងបញ្ញត្តិនិងលក្ខខណ្ឌដទៃទៀត។ រាល់វាក្យស័ព្ទ ដែលមិនត្រូវបានកំណត់និយមន័យនៅទីនេះ នឹងត្រូវមាននិយមន័យដូចមានកំណត់ក្នុងបញ្ញត្តិនិងលក្ខខណ្ឌទូទៅ។

តាមរយៈការចុះហត្ថលេខា/ផ្តិតស្នាមម្រាមដៃ លើទម្រង់ពាក្យសុំដាក់ប្រាក់បញ្ញើមានកាលកំណត់ ឬការចុចលើប៊ូតុង "យល់ព្រម (agree)" ឬ "ស្នើ(submit)" លើបណ្តាញឌីជីថលណាមួយរបស់ ធនាគារ ព្រីនស៍ ដែលអនុញ្ញាតឱ្យបើកគណនីបញ្ញើមានកាលកំណត់ លោកអ្នកយល់ព្រមគោរពនិងអនុវត្តតាមបញ្ញត្តិនិងលក្ខខណ្ឌនេះ ហើយបញ្ញត្តិ និងលក្ខខណ្ឌនេះ គឺជាកិច្ចព្រមព្រៀងរវាងលោកអ្នក និង ធនាគារ ព្រីនស៍ ។

លោកអ្នកអាចស្វែងរកព័ត៌មានលំអិតអំពីលក្ខណៈ និងអត្ថប្រយោជន៍ នៃគណនីសន្សំធម្មតា គណនីសន្សំឆ្លាតវៃ គណនីទ្វេទ្រព្យ នៅលើគេហទំព័រផ្លូវការរបស់ធនាគារយើង ឬទាក់ទងមកកាន់សេវាអតិថិជនរបស់ធនាគារយើង តាមរយៈលេខទូរស័ព្ទ ១៨០០ ២០ ៨៨៨៨ ឬតាមរយៈអាសយដ្ឋានអេឡិចត្រូនិក info@princebank.com.kh។

## ១. លក្ខខណ្ឌតម្រូវ លក្ខណៈ និងសំណើសុំបើកគណនីបញ្ញើមានកាលកំណត់

### ១.១. *គណនីបញ្ញើមានកាលកំណត់សម្រាប់បុគ្គល ឬអាជីវកម្ម*

១.១.១. លោកអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការស្នើសុំបើកគណនីបញ្ញើមានកាលកំណត់ ជារូបិយប័ណ្ណដុល្លាអាមេរិក ឬជារូបិវត្ថុប្រាក់រៀលខ្មែរ ជាមួយធនាគារយើង ប្រសិនបើលោកអ្នក៖

- ក. ជានិវាសនជន ឬអនិវាសនជន និងមានអាយុចាប់ពី១៨ឆ្នាំឡើង (សម្រាប់រូបវន្តបុគ្គល) ឬបានចុះបញ្ជី និងធ្វើអាជីវកម្មដោយស្របទៅតាមច្បាប់និងបទបញ្ញត្តិដែលមានជាធរមាន (សម្រាប់នីតិបុគ្គល)។
- ខ. បានបើក និងរក្សា គណនីសន្សំ ឬគណនីចរន្ត ជាមួយធនាគារយើង លើកលែងតែមានការយល់ព្រមផ្សេងពីនេះដោយធនាគារយើង។

គ. ដាក់ប្រាក់តម្កល់ដំបូង ទៅតាមការកំណត់ដោយ ធនាគារ ព្រីនស៍ និង ដែលត្រូវបានជូនដំណឹងទៅកាន់លោកអ្នក តាមរយៈមធ្យោបាយទំនាក់ទំនងដែលមានរបស់ធនាគារយើង រួមទាំងគេហទំព័រផ្លូវការរបស់ ធនាគារ ព្រីនស៍។

១.១.២. នៅពេលបើកគណនីបញ្ញើមានកាលកំណត់សម្រាប់បុគ្គល ឬអាជីវកម្ម លោកអ្នកយល់ព្រមថា៖

ក. អត្រាការប្រាក់អាចប្រែប្រួលទៅតាម រយៈពេលដាក់ប្រាក់បញ្ញើ រូបិយប័ណ្ណ និងរបៀបទូទាត់ការប្រាក់ដែលលោកនឹងអ្នកជ្រើសរើស។ ប្រសិនបើលោកអ្នកជ្រើសរើសទទួលការបង់ការប្រាក់ជាប្រចាំខែ នោះការប្រាក់នឹងផ្តល់ជូននៅថ្ងៃចុងក្រោយនៃខែ។ ដោយឡែក ប្រសិនបើលោកអ្នកជ្រើសរើសទទួលការបង់ការប្រាក់នៅចុងគ្រា នោះការប្រាក់នឹងផ្តល់ជូននៅថ្ងៃចុងគ្រានៃ រយៈពេលបញ្ញើ។ ប្រសិនបើលោកអ្នកជ្រើសរើសទទួលការបង់ការប្រាក់ជាមុន (សម្រាប់គណនីបញ្ញើមានកាលកំណត់សម្រាប់បុគ្គលប៉ុណ្ណោះ) នោះការប្រាក់នឹងផ្តល់ជូននៅថ្ងៃបើកគណនីបញ្ញើមានកាលកំណត់សម្រាប់បុគ្គល។ សូមកត់ចំណាំថា ការប្រាក់នឹងត្រូវបានបង់ដោយបញ្ចូលទៅក្នុងគណនីសន្សំ ឬគណនីចរន្តរបស់លោកអ្នក។

ខ. ប្រសិនបើលោកអ្នក មានបំណងដកប្រាក់ពីគណនីបញ្ញើមានកាលកំណត់ មុនកំណត់ លោកអ្នកត្រូវជូនដំណឹង មកកាន់ធនាគារយើងយ៉ាងតិច៣០ថ្ងៃជាមុន។ ហេតុនេះ ប្រសិនបើលោកអ្នកបិទគណនីបញ្ញើមានកាលកំណត់សម្រាប់បុគ្គល ឬអាជីវកម្មមុនកាលកំណត់ នៅក្នុងអំឡុងពេលពាក់កណ្តាលដំបូងនៃរយៈពេលបញ្ញើទាំងមូល ដោយមូលហេតុណាមួយ នោះលោកអ្នកទទួលបានត្រឹម ការប្រាក់មូលដ្ឋានដែលអនុវត្តចំពោះគណនីសន្សំ ឬគណនីចរន្តប៉ុណ្ណោះ (ការប្រាក់មួយណាដែលទាបជាងគេ)។ ប៉ុន្តែ ប្រសិនបើលោកអ្នកបិទគណនីបញ្ញើមានកាលកំណត់ នៅក្នុងអំឡុងពេលពាក់កណ្តាលចុងក្រោយនៃរយៈពេលបញ្ញើទាំងមូល នោះលោកអ្នកនឹងទទួលបាន អត្រាការប្រាក់ពាក់កណ្តាលនៃអត្រាការប្រាក់នៃគណនីបញ្ញើមានកាលកំណត់សម្រាប់បុគ្គលឬអាជីវកម្ម ដែលលោកអ្នកបានបិទនោះ។ ប្រសិនបើលោកអ្នក បិទគណនីបញ្ញើមានកាលកំណត់សម្រាប់បុគ្គលដោយភ្ជាប់ជាមួយរបៀបទូទាត់ការប្រាក់ជាមុន លោកអ្នកយល់ព្រមដោយមិនអាចដកហូតវិញបាន អនុញ្ញាតឱ្យ ធនាគារ ព្រីនស៍ កាត់ទឹកប្រាក់ដោយស្វ័យប្រវត្តិ និងដោយផ្ទាល់ ចេញពីគណនីបញ្ញើមានកាលកំណត់សម្រាប់បុគ្គលនោះ នូវទឹកប្រាក់ដែលមានចំនួនស្មើនឹងចំនួនការប្រាក់សរុបដែលបានផ្តល់ជូនលោកអ្នកជាមុន ដោយដកចេញនូវការប្រាក់ដែលលោកអ្នកត្រូវទទួល។

គ. ប្រសិនបើលោកអ្នកជ្រើសរើសយកជម្រើស "ប្រាក់ដើមតែប៉ុណ្ណោះ" ក្នុងលក្ខខណ្ឌដាក់បញ្ញើឡើងវិញ ធនាគារយើងនឹងបង់ការប្រាក់ដោយបញ្ចូលការប្រាក់ដែលលោកអ្នកត្រូវទទួល ទៅក្នុងគណនីសន្សំ ឬគណនីចរន្តរបស់លោកអ្នកនៅកាលបរិច្ឆេទទូទាត់ ហើយចំនួនប្រាក់ដើមនឹងត្រូវបន្តប្រើប្រាស់សម្រាប់រយៈពេលបញ្ញើថ្មីដែលមានរយៈពេលស្មើគ្នាទៅនឹងរយៈពេលនៃបញ្ញើលើកដំបូង។ ប្រសិនបើលោកអ្នកជ្រើសរើសយកជម្រើស "ប្រាក់ដើម+ការប្រាក់" ក្នុងលក្ខខណ្ឌដាក់បញ្ញើឡើងវិញ ការប្រាក់នឹងត្រូវបូកបញ្ចូលទៅក្នុងប្រាក់

ដើមរបស់លោកអ្នកនៅកាលបរិច្ឆេទទូទាត់ ហើយនឹងត្រូវក្លាយជាប្រាក់ដើមថ្មី ដែលនឹងត្រូវបន្តប្រើប្រាស់សម្រាប់រយៈពេលបញ្ញើថ្មីដែលមានរយៈពេលស្មើនឹងរយៈពេលនៃបញ្ញើលើកដំបូង។

ឃ. លោកអ្នកអាចបញ្ចូលទឹកប្រាក់បន្ថែម ទៅក្នុងគណនីបញ្ញើមានកាលកំណត់របស់លោកអ្នក នៅគ្រប់ពេលវេលា នៅតាមសាខាប្រតិបត្តិការរបស់ធនាគារយើង ឬតាមរយៈមធ្យោបាយឌីជីថលដែលមានរបស់ធនាគារយើង ប្រសិនបើការប្រាក់ត្រូវបង់ជូនជាប្រចាំខែ ឬនៅចុងគ្រា។

១.២. ***គណនីសន្សំឆ្លាតវៃ***

១.២.១. ប្រសិនបើលោកអ្នកជារូបវន្តបុគ្គល (និវាសនជន ឬអនិវាសនជន) ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ លោកអ្នកអាចស្នើសុំបើកគណនីសន្សំឆ្លាតវៃ ជារូបិយប័ណ្ណដុល្លារអាមេរិក និង/ឬរូបិយវត្ថុប្រាក់រៀល ហើយលោកអ្នកអាចជ្រើសរើសយកប្រភេទណាមួយនៃ គណនីបញ្ញើមានកាលកំណត់ ដូចខាងក្រោម៖

ក. គណនីសន្សំឆ្លាតវៃគម្រោង Silver

ខ. គណនីសន្សំឆ្លាតវៃគម្រោង Gold

គ. គណនីសន្សំឆ្លាតវៃគម្រោង Emerald

ឃ. គណនីសន្សំឆ្លាត បៀលជី ឆ្នាំទី១

ង. គណនីសន្សំឆ្លាត បៀលជី ឆ្នាំទី២

១.២.២. នៅពេលបើកគណនីសន្សំឆ្លាតវៃ ជាមួយធនាគារយើង លោកអ្នកយល់ព្រមថា៖

ក. លោកអ្នកត្រូវដាក់ទឹកប្រាក់តម្កល់ដំបូង ដែលបានកំណត់ ទៅតាមប្រភេទនៃគម្រោងនីមួយៗនៃគណនីសន្សំឆ្លាតវៃ។

ខ. លោកអ្នកត្រូវបញ្ចូលទឹកប្រាក់អប្បបរមាប្រចាំខែ ទៅតាមប្រភេទនៃគម្រោងនីមួយៗនៃគណនីសន្សំឆ្លាតវៃរបស់លោកអ្នក នៅកាលបរិច្ឆេទកំណត់នៃខែនីមួយៗ។ កាលបរិច្ឆេទកំណត់ដំបូង គឺនៅខែបន្ទាប់ នៃកាលបរិច្ឆេទបើកគណនី ហើយកាលបរិច្ឆេទកំណត់បន្ទាប់ គឺរយៈពេល១ខែ បន្ទាប់ពីកាលបរិច្ឆេទកំណត់នៃខែមុនៗ (ឧទាហរណ៍៖ ប្រសិនបើលោកអ្នកបើកគណនីសន្សំឆ្លាតវៃ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ នោះកាលបរិច្ឆេទកំណត់ដំបូងក្នុងការបង់ទឹកប្រាក់អប្បបរមាប្រចាំខែ គឺនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣។ សូមកត់សម្គាល់ថា ប្រសិនបើលោកអ្នកបើកគណនីសន្សំឆ្លាតវៃ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ នោះកាលបរិច្ឆេទកំណត់ដំបូងក្នុងការបង់ទឹកប្រាក់អប្បបរមាប្រចាំខែគឺនៅថ្ងៃចុងក្រោយបង្អស់នៃខែបន្ទាប់ ដែលបានន័យថា គឺនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣)។ ទោះបីលោកអ្នកបញ្ចូលទឹកប្រាក់អប្បបរមាប្រចាំខែនៅមុនកាលបរិច្ឆេទកំណត់ក៏ដោយ ក៏កាលបកាលបរិច្ឆេទកំណត់ក្នុងការបង់បញ្ចូលទឹកប្រាក់អប្បបរមាប្រចាំខែសម្រាប់ខែបន្ទាប់ៗទៀតនឹងរក្សានៅដដែល។ ប្រសិនបើលោកអ្នកខកខានក្នុងការបញ្ចូលទឹកប្រាក់អប្បបរមាប្រចាំខែនៅកាលបរិច្ឆេទកំណត់ណាមួយ ឬក្នុងរយៈពេលអនុគ្រោះ១៤(ដប់បួន)ថ្ងៃនៃថ្ងៃប្រតិទិន

គិតចាប់ពីកាលបរិច្ឆេទកំណត់នីមួយៗ គិតត្រឹមម៉ោង៣រសៀល (ចំពោះ គណនីសន្សំឆ្លាតវៃគម្រោង Silver គណនីសន្សំឆ្លាតវៃគម្រោង Gold និង គណនីសន្សំឆ្លាតវៃគម្រោង Emerald) និងត្រឹមម៉ោង៥រសៀល (ចំពោះគណនីសន្សំឆ្លាត បៀលជី ឆ្នាំទី១ និងគណនីសន្សំឆ្លាត បៀលជី ឆ្នាំទី២) លោកអ្នកយល់ព្រមអនុញ្ញាតឱ្យ ធនាគារ ព្រីនស៍ បិទគណនីសន្សំឆ្លាតវៃរបស់លោកអ្នកដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់មានការយល់ព្រមបន្ថែមពីលោកអ្នកឡើយ ។

គ. ចំពោះការបញ្ចូលទឹកប្រាក់ប្រចាំខែនីមួយៗ លោកអ្នកអាចបញ្ចូលលើសពីចំនួនទឹកប្រាក់អប្បបរមាប្រចាំខែដែលកំណត់ សម្រាប់ខែទី១ ដល់ខែទី១០។ ប៉ុន្តែ ចាប់ពីខែទី១១ ដល់ខែទី១២ នៃគម្រោងនីមួយៗ និងឆ្នាំនីមួយៗ នៃគណនីសន្សំឆ្លាតវៃ លោកអ្នកអាចបញ្ចូលត្រឹមទឹកប្រាក់ ដែលមានចំនួនស្មើនឹងទឹកប្រាក់អប្បបរមាប្រចាំខែដែលបានកំណត់ក្នុងគម្រោងនីមួយៗ និងនៃឆ្នាំនីមួយៗ នៃគណនីសន្សំឆ្លាតវៃរបស់លោកអ្នកតែប៉ុណ្ណោះ។

ឃ. អនុញ្ញាតឱ្យធនាគារយើង ធ្វើការកាត់ទឹកប្រាក់អប្បបរមាប្រចាំខែ ចេញពីគណនីសន្សំ ឬគណនីចរន្តណាមួយរបស់លោកអ្នកដោយស្វ័យប្រវត្តិ ("**គណនីដែលត្រូវបានកំណត់**") នៅកាលបរិច្ឆេទកំណត់នីមួយៗ។ លោកអ្នកត្រូវធានាថា គណនីដែលត្រូវបានកំណត់មានសមតុល្យគ្រប់គ្រាន់សម្រាប់ការកាត់ប្រាក់នេះ។

ង. លោកអ្នកនឹងទទួលបានអត្រាការប្រាក់មូលដ្ឋាន (Basic Interest Rate) ដែលនឹងត្រូវគណនាលើទឹកប្រាក់តម្កល់ដំបូង និងលើទឹកប្រាក់ដែលបានដាក់បញ្ចូលសម្រាប់ខែមុនៗ គិតចាប់ពីកាលបរិច្ឆេទតម្កល់ទឹកប្រាក់ ប្រសិនបើលោកអ្នកបិទគណនីឆ្លាតវៃមុនពេលកំណត់។

ច. លោកអ្នកនឹងទទួលបានអត្រាការប្រាក់លើចំនួនទឹកប្រាក់ដែលបានបញ្ចូល (Top Up Interest Rate) ដែលនឹងត្រូវគណនាតែទៅលើចំនួនទឹកប្រាក់ដែលបានបញ្ចូលថ្មី សម្រាប់ខែដែលបញ្ចូលទឹកប្រាក់នោះប៉ុណ្ណោះ។

ឆ. ការប្រាក់នឹងត្រូវបង្គរជាប្រចាំថ្ងៃ ហើយត្រូវបង់ជាប្រចាំខែ ទៅក្នុងគណនីសន្សំ ឬគណនីចរន្តរបស់លោកអ្នកដែលមានជាមួយធនាគារយើងដោយស្វ័យប្រវត្តិ។

ជ. លោកអ្នក ឬអ្នកទទួលផលណាមួយដែលលោកអ្នកបានជ្រើសរើស នឹងទទួលបានការការពារពីកញ្ចប់ធានារ៉ាប់រងសុខភាព (Medical Care Insurance) (នៅពេលបើកគណនីសន្សំឆ្លាតវៃគម្រោង Silver គណនីសន្សំឆ្លាតវៃគម្រោង Gold និង គណនីសន្សំឆ្លាតវៃគម្រោង Emerald) ហើយលោកអ្នកនឹងទទួលបានការការពារពីកញ្ចប់ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល (នៅពេលបើកចំពោះគណនីសន្សំឆ្លាត បៀលជី ឆ្នាំទី១ និងគណនីសន្សំឆ្លាត បៀលជី ឆ្នាំទី២) ទៅតាមប្រភេទនីមួយៗនៃ គណនីសន្សំឆ្លាតវៃដែលលោកអ្នកបានបើក និងស្របទៅតាមកិច្ចសន្យាធានារ៉ាប់រងដែលពាក់ព័ន្ធនីមួយៗ ដែលធនាគារយើងបានទិញជូនលោកអ្នក ហើយលោកអ្នកយល់ព្រម ឬធានាថាអត្ថគាហកៈនៃកិច្ចសន្យាធានារ៉ាប់រងយល់ព្រម អនុវត្តកាតព្វកិច្ចនានា ដែលមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រងសុខភាព ឬ

ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល ដែលត្រូវបានទិញនោះ។ លោកអ្នកទទួលស្គាល់ថា កិច្ចសន្យាធានារ៉ាប់រងអាចត្រូវបានបញ្ចប់ដោយក្រុមហ៊ុនធានារ៉ាប់រង នៅពេលណាមួយ ប្រសិនបើលោកអ្នក ឬអត្ថគាហកៈនៃកិច្ចសន្យាធានារ៉ាប់រង មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនដែលមានក្នុងកិច្ចសន្យាធានារ៉ាប់រង ទោះក្នុងទម្រង់បែបណាក៏ដោយ ឬដោយមូលហេតុផ្សេងទៀត ដែលមិនពាក់ព័ន្ធនឹងធនាគារយើង ហើយលោកអ្នកយល់ព្រមថា ធនាគារយើងនឹងមិនទទួលខុសត្រូវ ចំពោះការបញ្ចប់នៃកិច្ចសន្យាធានារ៉ាប់រងនេះ ឡើយ។ ប្រសិនបើគណនីសន្សំឆ្លាតវៃរបស់លោកអ្នកជាគណនីរួម លោកអ្នកយល់ព្រមថា មានតែម្ចាស់គណនីរួមម្នាក់ប៉ុណ្ណោះ ដែលទទួលបាននូវការការពារពីកញ្ចប់ធានារ៉ាប់រងសុខភាព/ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គលនេះ ហើយក្នុងករណីនេះ ម្ចាស់គណនីរួមទាំងអស់ត្រូវព្រមព្រៀងគ្នា និងជូនដំណឹងមកកាន់ធនាគារយើង អំពីឈ្មោះអត្ថគាហកៈដែលត្រូវទទួលបានការការពារពីកញ្ចប់ធានារ៉ាប់រងសុខភាព ឬ ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គលនេះ។

ឈ. អនុញ្ញាតឱ្យធនាគារយើង៖

(១) កំណត់ និងកែប្រែចំនួនទឹកប្រាក់អប្បបរមាប្រចាំខែ នៅគ្រប់ពេលវេលា ដោយធ្វើការជូនដំណឹងទៅកាន់លោកអ្នកតាមរយៈមធ្យោបាយទំនាក់ទំនងដែលមានរបស់ធនាគារយើង។

(២) កែប្រែអត្រាការប្រាក់ រួមទាំងអត្រាការប្រាក់មូលដ្ឋាន អត្រាការប្រាក់លើចំនួនទឹកប្រាក់ដែលបានបញ្ចូល និងអត្រាការប្រាក់បន្ថែមដទៃទៀតទាំងរូបិយប័ណ្ណដុល្លារអាមេរិក ឬរូបិយវត្ថុប្រាក់រៀល នៅគ្រប់ពេលវេលា ដោយធ្វើការជូនដំណឹងទៅកាន់លោក អ្នកតាមរយៈមធ្យោបាយទំនាក់ទំនងដែលមានរបស់ធនាគារយើង និងដោយមិនចាំបាច់មានការយល់ព្រមបន្ថែម ពីលោកអ្នកឡើយ។

(៣) ទិញកញ្ចប់ធានារ៉ាប់រងសុខភាព ឬ ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល ក្នុងនាមលោកអ្នក ដើម្បីដាក់ដំណើរការដោយស្វ័យប្រវត្តិនូវកិច្ចសន្យាធានារ៉ាប់រង ទៅតាមការចាំបាច់ ដោយមិនចាំបាច់មានការយល់ព្រមបន្ថែមពីលោកអ្នកឡើយ។

ញ. គម្រោងគណនីសន្សំឆ្លាតវៃរបស់លោកអ្នក នឹងត្រូវបានបន្តដំឡើងគម្រោង ដោយស្វ័យប្រវត្តិនៅឆ្នាំបន្តបន្ទាប់ (ឧទាហរណ៍៖ ប្រសិនបើលោកអ្នកបើកគណនីសន្សំឆ្លាតវៃគម្រោង Silver នោះគណនីរបស់លោកអ្នកនឹងត្រូវបានបន្តដំឡើងគម្រោង ទៅគណនីសន្សំឆ្លាតវៃគម្រោង Gold និងបន្តបន្ទាប់ទៅគណនីសន្សំឆ្លាតវៃគម្រោង Emerald ដោយស្វ័យប្រវត្តិ។ ប្រសិនបើលោកអ្នកបើកគណនីសន្សំឆ្លាតវៃគម្រោង Gold នោះគណនីរបស់លោកអ្នកនឹងត្រូវបានបន្តដំឡើងគម្រោង ទៅគណនីសន្សំឆ្លាតវៃគម្រោង Emerald ដោយស្វ័យប្រវត្តិ។)។ ប្រសិនបើគណនីសន្សំឆ្លាតវៃរបស់អ្នកជាប្រភេទគម្រោង Emerald នោះគណនីរបស់លោកអ្នកនឹងត្រូវបិទនៅចុងគ្រា។ ប្រសិនបើលោកអ្នកបើកគណនីសន្សំឆ្លាត បៀលដឺ ឆ្នាំទី១ នោះគណនីរបស់លោកអ្នកនឹងត្រូវបានបន្តដំឡើងទៅជាគណនីសន្សំឆ្លាត បៀលដឺ ឆ្នាំទី២។ ប្រសិនបើលោកអ្នកបើកគណនីសន្សំឆ្លាត បៀលដឺ ឆ្នាំទី២ នោះគណនី

របស់លោកអ្នកនឹងត្រូវបិទនៅចុងគ្រា)។ ប្រសិនបើលោកអ្នកមិនមានបំណងបន្តដំឡើងគម្រោងគណនីសន្សំឆ្លាតវៃរបស់ខ្លួនទេ លោកអ្នកត្រូវជូនដំណឹងមកធនាគារយើង យ៉ាងតិច១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃប្រតិទិន មុនកាលកំណត់នៃគម្រោងនីមួយៗ ដើម្បីអាចបិទគណនីសន្សំឆ្លាតវៃរបស់លោកអ្នកនៅកាលកំណត់បាន បើមិនដូច្នោះទេ គណនីសន្សំឆ្លាតវៃរបស់លោកអ្នក នឹងត្រូវបានបន្តដំឡើងគម្រោង ដោយស្វ័យប្រវត្តិទៅគម្រោងឬឆ្នាំបន្ទាប់ ហើយក្នុងករណីដែលលោកអ្នកបិទគណនីសន្សំឆ្លាតវៃមុនកាលកំណត់ ប្រការ១.២.២.ដ ខាងក្រោមត្រូវអនុវត្ត។

ដ. ប្រសិនបើលោកអ្នកបិទគណនីសន្សំឆ្លាតវៃរបស់លោកអ្នក នៅមុនកាលកំណត់ ឬប្រសិនបើគណនីសន្សំឆ្លាតវៃរបស់លោកអ្នក ត្រូវបានធនាគារយើងបិទនៅមុនកាលកំណត់ ដោយអនុលោមតាមបញ្ញត្តិនិងលក្ខខណ្ឌនេះ លោកអ្នកនឹងទទួលបានត្រឹមតែអត្រាការប្រាក់មូលដ្ឋាន សម្រាប់ប្រាក់ដើម និងទឹកប្រាក់បញ្ចូលទាំងអស់។ ក្នុងករណីនេះ លោកអ្នកយល់ព្រមអនុញ្ញាតឱ្យធនាគារយើង គណនាការប្រាក់សារជាថ្មី និងកាត់ប្រាក់ដោយផ្ទាល់និងដោយស្វ័យប្រវត្តិចេញពីគណនីសន្សំឆ្លាតវៃរបស់លោកអ្នក នូវចំនួនទឹកប្រាក់ដែលស្មើនឹង ចំនួនទឹកប្រាក់នៃការប្រាក់សរុបដែលបានបង់ជូនលោកអ្នក ដកចេញនូវចំនួនទឹកប្រាក់នៃការប្រាក់ជាក់ស្តែងដែលលោកអ្នកត្រូវទទួល កម្រៃសេវាលើការបិទគណនីមុនកាលកំណត់ទៅតាមប្រភេទគណនីឆ្លាតវៃ និងកម្រៃសេវាផ្សេងទៀត ដូចបានជូនដំណឹងទៅកាន់លោកអ្នក មុនពេលបញ្ចូលទឹកប្រាក់ដែលនៅសល់ ទៅក្នុងគណនីសន្សំ ឬគណនីចរន្តរបស់លោកអ្នក។

១.៣. ***គណនីទ្វេទ្រព្យ***

១.៣.១. ប្រសិនបើលោកអ្នកជាអតិថិជនធនាគារអាទិភាពរបស់ធនាគារយើងខ្ញុំ លោកអ្នកអាចស្នើសុំបើកគណនីទ្វេទ្រព្យ ជារូបិយប័ណ្ណដុល្លារអាមេរិក និង/ឬ រូបិយវត្ថុប្រាក់រៀល សម្រាប់រយៈពេល២(ពីរ)ឆ្នាំ ហើយលោកអ្នកអាចជ្រើសរើសយកប្រភេទណាមួយនៃ គណនីបញ្ញើមានកាលកំណត់ ដូចខាងក្រោម៖

ក. គណនីទ្វេទ្រព្យសម្រាប់កញ្ចប់បុគ្គល

ខ. គណនីទ្វេទ្រព្យសម្រាប់កញ្ចប់គ្រួសារ

១.៣.២. នៅពេលបើកគណនីទ្វេទ្រព្យ ជាមួយធនាគារយើង លោកអ្នកយល់ព្រមថា៖

ក. លោកអ្នកត្រូវដាក់ទឹកប្រាក់តម្កល់ដំបូង ដែលបានកំណត់ ទៅតាមប្រភេទនៃគណនីទ្វេទ្រព្យនីមួយៗ។

ខ. លោកអ្នកត្រូវបញ្ចូលទឹកប្រាក់អប្បបរមាប្រចាំខែ ទៅតាមប្រភេទនៃគណនីទ្វេទ្រព្យរបស់លោកអ្នក នៅកាលបរិច្ឆេទកំណត់នៃខែនីមួយៗ។ កាលបរិច្ឆេទកំណត់ដំបូង គឺនៅខែបន្ទាប់ នៃកាលបរិច្ឆេទបើកគណនី ហើយកាលបរិច្ឆេទកំណត់បន្ទាប់ គឺរយៈពេល១ខែបន្ទាប់ពីកាលបរិច្ឆេទកំណត់នៃខែមុនៗ (ឧទាហរណ៍៖ ប្រសិនបើលោកអ្នកបើកគណនីទ្វេទ្រព្យ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ នោះកាលបរិច្ឆេទកំណត់ដំបូងក្នុងការបង់ទឹកប្រាក់

អប្បបរមាប្រចាំខែ គឺនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣។ សូមកត់សម្គាល់ថា ប្រសិនបើលោកអ្នកបើកគណនីសន្សំទ្វេទ្រព្យ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤ នោះកាលបរិច្ឆេទកំណត់ដំបូងក្នុងការបង់ទឹកប្រាក់អប្បបរមាប្រចាំខែគឺនៅថ្ងៃចុងក្រោយបង្អស់នៃខែបន្ទាប់ ដែលបានន័យថា គឺនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤)។ ទោះបីលោកអ្នកបញ្ចូលទឹកប្រាក់អប្បបរមាប្រចាំខែនៅមុនកាលបរិច្ឆេទកំណត់ក៏ដោយ ក៏កាលបកាលបរិច្ឆេទកំណត់ក្នុងការបង់បញ្ចូលទឹកប្រាក់អប្បបរមាប្រចាំខែសម្រាប់ខែបន្ទាប់ៗទៀតនឹងរក្សានៅដដែល។ ប្រសិនបើលោកអ្នក ខកខានក្នុងការបញ្ចូលទឹកប្រាក់អប្បបរមាប្រចាំខែ នៅកាលបរិច្ឆេទកំណត់ណាមួយ ឬក្នុងរយៈពេលអនុគ្រោះ១៤(ដប់ប្រាំ)ថ្ងៃនៃថ្ងៃប្រតិទិន គិតចាប់ពីកាលបរិច្ឆេទកំណត់នីមួយៗ គិតត្រឹមម៉ោង៣រសៀល លោកអ្នកយល់ព្រមអនុញ្ញាតឱ្យ ធនាគារព្រីនស៍ បិទគណនីទ្វេទ្រព្យរបស់លោកអ្នកដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់មានការយល់ព្រមបន្ថែមពីលោកអ្នកឡើយ (ឧទាហរណ៍៖ ប្រសិនបើកាលបរិច្ឆេទកំណត់សម្រាប់ការបញ្ចូលទឹកប្រាក់អប្បបរមាប្រចាំខែ ត្រូវនឹងថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ លោកអ្នកត្រូវបានអនុគ្រោះឱ្យធ្វើការបញ្ចូលទឹកប្រាក់អប្បបរមាប្រចាំខែ រហូតដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០២៣ ត្រឹមម៉ោង៣រសៀល)។

គ. ចំពោះការបញ្ចូលទឹកប្រាក់ប្រចាំខែនីមួយៗ លោកអ្នកអាចបញ្ចូលលើសពីចំនួនទឹកប្រាក់អប្បបរមាប្រចាំខែដែលកំណត់ សម្រាប់ខែទី២ ដល់ខែទី២២។ ប៉ុន្តែ ចាប់ពីខែទី២៣ ដល់ខែទី២៤ នៃគណនីទ្វេទ្រព្យ លោកអ្នកអាចបញ្ចូលត្រឹមទឹកប្រាក់ ដែលមានចំនួនស្មើនឹងទឹកប្រាក់អប្បបរមាប្រចាំខែដែលបានកំណត់នៃគណនីទ្វេទ្រព្យរបស់លោកអ្នកតែប៉ុណ្ណោះ។

ឃ. អនុញ្ញាតឱ្យធនាគារយើង ធ្វើការកាត់ទឹកប្រាក់អប្បបរមាប្រចាំខែ ចេញពីគណនីធនាគារអាទិភាពរបស់លោកអ្នកដោយស្វ័យប្រវត្តិ ("**គណនីដែលត្រូវបានកំណត់**") នៅកាលបរិច្ឆេទកំណត់នីមួយៗ។ លោកអ្នកត្រូវធានាថា គណនីដែលត្រូវបានកំណត់មានសមតុល្យគ្រប់គ្រាន់សម្រាប់ការកាត់ប្រាក់នេះ។

ង. លោកអ្នកនឹងទទួលបានអត្រាការប្រាក់មូលដ្ឋាន (Basic Interest Rate) ដែលនឹងត្រូវគណនាលើទឹកប្រាក់តម្កល់ដំបូង និងលើទឹកប្រាក់ដែលបានដាក់បញ្ចូលសម្រាប់ខែមុនៗ គិតចាប់ពីកាលបរិច្ឆេទតម្កល់ទឹកប្រាក់ ប្រសិនបើលោកអ្នកបិទគណនីទ្វេទ្រព្យមុនពេលកំណត់។

ច. លោកអ្នកនឹងទទួលបានអត្រាការប្រាក់លើចំនួនទឹកប្រាក់ដែលបានបញ្ចូល (Top Up Interest Rate) ដែលនឹងត្រូវគណនាតែទៅលើចំនួនទឹកប្រាក់ដែលបានបញ្ចូលថ្មី សម្រាប់ខែដែលបញ្ចូលទឹកប្រាក់នោះប៉ុណ្ណោះ។

ឆ. ការប្រាក់នឹងត្រូវបង្គរជាប្រចាំថ្ងៃ ហើយត្រូវបង់ជាប្រចាំខែ ទៅក្នុងគណនីអាទិភាពរបស់លោកអ្នកដែលមានជាមួយធនាគារយើងដោយស្វ័យប្រវត្តិ។

ជ. លោកអ្នក ឬអ្នកទទួលផលណាមួយដែលលោកអ្នកបានជ្រើសរើស នឹងទទួលបានការការពារពីកញ្ចប់ធានារ៉ាប់រងសុខភាព (Medical Care Insurance) ទៅតាមប្រភេទ

នីមួយៗនៃគណនីទ្វេទ្រព្យដែលលោកអ្នកបានបើក និងស្របទៅតាមកិច្ចសន្យាធានារ៉ាប់រងដែលពាក់ព័ន្ធនីមួយៗ ដែលធនាគារយើងបានទិញជូន ហើយលោកអ្នកយល់ព្រមអនុវត្តកាតព្វកិច្ចនានា ឬធានាថាអ្នកទទួលផលនៃកិច្ចសន្យាធានារ៉ាប់រងយល់ព្រម អនុវត្តកាតព្វកិច្ចនានា ដែលមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រងសុខភាព ដែលត្រូវបានទិញនោះ។ លោកអ្នកទទួលស្គាល់ថា កិច្ចសន្យាធានារ៉ាប់រង អាចត្រូវបានបញ្ចប់ដោយក្រុមហ៊ុនធានារ៉ាប់រង នៅពេលណាមួយ ប្រសិនបើលោកអ្នក ឬអត្ថគាហកៈនៃកិច្ចសន្យាធានារ៉ាប់រង មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនដែលមានក្នុងកិច្ចសន្យាធានារ៉ាប់រង ទោះក្នុងទម្រង់បែបណាក៏ដោយ ឬដោយមូលហេតុផ្សេងទៀត ដែលមិនពាក់ព័ន្ធនឹងធនាគារយើង ហើយលោកអ្នកយល់ព្រមថា ធនាគារយើងនឹងមិនទទួលខុសត្រូវ ចំពោះការបញ្ចប់នៃកិច្ចសន្យាធានារ៉ាប់រងនេះឡើយ។ ប្រសិនបើគណនីសន្សំទ្វេទ្រព្យរបស់លោកអ្នកជាគណនីរួម លោកអ្នកយល់ព្រមថា មានតែអ្នកទទួលផលតែម្នាក់ប៉ុណ្ណោះ ដែលទទួលបាននូវការការពារពីកញ្ចប់ធានារ៉ាប់រងសុខភាពនេះ ហើយក្នុងករណីនេះ ម្ចាស់គណនីរួមទាំងអស់ត្រូវព្រមព្រៀងគ្នា និងជូនដំណឹងមកកាន់ធនាគារយើង អំពីឈ្មោះអ្នកទទួលផល ដែលត្រូវទទួលបានការការពារពីកញ្ចប់ធានារ៉ាប់រងសុខភាពនេះ ដែលឈ្មោះអ្នកទទួលផលនេះ មិនអាចត្រូវបានកែប្រែឡើយ បន្ទាប់ពីបានចុះបញ្ជីជាអ្នកទទួលផលនៃកញ្ចប់ធានារ៉ាប់រងសុខភាពនេះរួចហើយ ។

ឈ. អនុញ្ញាតឱ្យធនាគារយើង៖

(១) កំណត់ និងកែប្រែចំនួនទឹកប្រាក់អប្បបរមាប្រចាំខែ នៅគ្រប់ពេលវេលា ដោយធ្វើការជូនដំណឹងទៅកាន់លោកអ្នកតាមរយៈមធ្យោបាយទំនាក់ទំនងដែលមានរបស់ធនាគារយើង។

(២) កែប្រែអត្រាការប្រាក់ រួមទាំងអត្រាការប្រាក់មូលដ្ឋាន អត្រាការប្រាក់លើចំនួនទឹកប្រាក់ដែលបានបញ្ចូល និងអត្រាការប្រាក់បន្ថែមដទៃទៀត ទាំងរូបិយប័ណ្ណដុល្លារអាមេរិក ឬរូបិយវត្ថុប្រាក់រៀល នៅគ្រប់ពេលវេលា ដោយធ្វើការជូនដំណឹងទៅកាន់លោក អ្នកតាមរយៈមធ្យោបាយទំនាក់ទំនងដែលមានរបស់ធនាគារយើង និងដោយមិនចាំបាច់មានការយល់ព្រមបន្ថែម ពីលោកអ្នកឡើយ។

(៣) ទិញកញ្ចប់ធានារ៉ាប់រងសុខភាព ក្នុងនាមលោកអ្នក ដើម្បីដាក់ដំណើរការដោយស្វ័យប្រវត្តិនូវកិច្ចសន្យាធានារ៉ាប់រង ទៅតាមការចាំបាច់ ដោយមិនចាំបាច់មានការយល់ព្រមបន្ថែមពីលោកអ្នកឡើយ។

ញ. គណនីទ្វេទ្រព្យរបស់លោកអ្នក នឹងត្រូវបានបន្តដោយស្វ័យប្រវត្តិ សម្រាប់រយៈពេល២(ពីរ) ឆ្នាំជាបន្តបន្ទាប់ទៀត នៅរាល់ពេលដែលគណនីនេះផុតកំណត់។ ប្រសិនបើលោកអ្នក មិនមានបំណងបន្តរយៈពេលនៃគណនីទ្វេទ្រព្យរបស់លោកអ្នកទេ លោកអ្នកត្រូវជូនដំណឹងមកកាន់ធនាគារយើង យ៉ាងតិច១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃប្រតិទិន មុនកាលកំណត់នៃគណនីទ្វេទ្រព្យរបស់លោកអ្នក ដើម្បីអាចបិទគណនីទ្វេទ្រព្យរបស់លោកអ្នកនៅកាលកំណត់បាន បើមិនដូច្នោះទេ គណនីទ្វេទ្រព្យរបស់លោកអ្នក នឹងត្រូវបានបន្តរយៈពេល ដោយ

ស្វ័យប្រវត្តិ ហើយក្នុងករណីដែលលោកអ្នកបិទគណនីសន្សំទ្វេទ្រព្យមុនកាលកំណត់ ប្រការ១.៣.២.ដ ខាងក្រោមត្រូវអនុវត្ត។

ដ. ប្រសិនបើលោកអ្នកបិទគណនីទ្វេទ្រព្យរបស់លោកអ្នក នៅមុនកាលកំណត់ ឬប្រសិនបើគណនីទ្វេទ្រព្យរបស់លោកអ្នក ត្រូវបានធនាគារយើងបិទនៅមុនកាលកំណត់ ដោយអនុលោមតាមបញ្ញត្តិនិងលក្ខខណ្ឌនេះ លោកអ្នកនឹងទទួលបានត្រឹមតែអត្រាការប្រាក់មូលដ្ឋាន សម្រាប់ប្រាក់ដើម និងទឹកប្រាក់បញ្ចូលទាំងអស់ តែប៉ុណ្ណោះ។ ក្នុងករណីនេះ លោកអ្នកយល់ព្រមអនុញ្ញាតឱ្យធនាគារយើង គណនាការប្រាក់សារជាថ្មី និងកាត់ប្រាក់ដោយផ្ទាល់និងដោយស្វ័យប្រវត្តិចេញពីគណនីទ្វេទ្រព្យរបស់លោកអ្នក នូវចំនួនទឹកប្រាក់ដែលស្មើនឹង ចំនួនទឹកប្រាក់នៃការប្រាក់សរុបដែលបានបង់ជូនលោកអ្នក ដកចេញនូវចំនួនទឹកប្រាក់នៃការប្រាក់ជាក់ស្តែងដែលលោកអ្នកត្រូវទទួល កម្រៃសេវាលើការបិទគណនីមុនកាលកំណត់ទៅតាមប្រភេទនៃគណនីទ្វេទ្រព្យ និងកម្រៃសេវាផ្សេងទៀត ដូចបានជូនដំណឹងទៅកាន់លោកអ្នក មុនពេលធ្វើការបញ្ចូលទឹកប្រាក់ដែលនៅសល់ ទៅក្នុងគណនីធនាគារអាទិភាពរបស់លោកអ្នក។

១.៤. លោកអ្នកអាចបើកគណនីបញ្ញើមានកាលកំណត់ណាមួយ ឬបញ្ចូលទឹកប្រាក់ទៅក្នុងគណនីបញ្ញើមានកាលកំណត់ដែលមានស្រាប់ នៅក្នុងម៉ោងប្រតិបត្តិការ នៅសាខាប្រតិបត្តិការណាមួយរបស់ធនាគារធនាគារយើង ឬតាមរយៈមធ្យោបាយឌីជីថលដែលមានរបស់ធនាគារយើង។

១.៥. សម្រាប់គណនីបញ្ញើមានកាលកំណត់ ដែលលោកអ្នកបានបើករួមជាមួយបុគ្គលដទៃទៀត គ្រប់ម្ចាស់គណនីរួមទាំងអស់ ត្រូវផ្តល់អាណត្តិគណនី សម្រាប់ប្រតិបត្តិការនៃគណនី និងការបិទគណនី ("**អាណត្តិគណនី**")។ ផ្អែកតាមការអនុម័តយល់ព្រមរបស់ធនាគារយើង ម្ចាស់គណនីរួម អាចស្នើសុំផ្លាស់ប្តូរអាណត្តិគណនីដែលមានស្រាប់ ដោយត្រូវអញ្ជើញមកកាន់សាខាប្រតិបត្តិណាមួយរបស់ធនាគារយើង។ ក្នុងនាមជាម្ចាស់គណនីរួម លោកអ្នកយល់ និងព្រមព្រៀងថា៖

ក. សមតុល្យនៅក្នុងគណនីបញ្ញើមានកាលកំណត់ ត្រូវបានកាន់កាប់រួមគ្នាដោយម្ចាស់គណនីរួមទាំងអស់ ហើយម្ចាស់គណនីរួមនីមួយៗ ត្រូវទទួលខុសត្រូវជាសាមគ្គី (joint and several liability) លើប្រតិបត្តិការទាំងអស់ ដែលត្រូវបានធ្វើឡើងក្រោមគណនីនេះ ទោះបីជាមានការខ្វែងគំនិតគ្នា ឬវិវាទ ឬការរៀបចំផ្សេងទៀតក្នុងចំណោមម្ចាស់គណនីរួមទាំងអស់ ក៏ដោយ។

ខ. ដើម្បីជាប្រយោជន៍ដល់ម្ចាស់គណនីរួមទាំងអស់ ធនាគារយើង អាច(ប៉ុន្តែមិនតម្រូវឱ្យ) ធ្វើការផ្ទៀងផ្ទាត់ការបញ្ជាណាមួយ (រួមបញ្ចូលទាំងការបិទគណនីរួម) ដែលត្រូវបានផ្តួចផ្តើមដោយម្ចាស់គណនីរួមណាមួយ តាមរយៈវិធីសាស្ត្រផ្ទៀងផ្ទាត់ដែលសមរម្យ ឬអាចតម្រូវឱ្យម្ចាស់គណនីរួមទាំងអស់ផ្តល់ការយល់ព្រមលើការបញ្ជាណាមួយ មុនពេលធនាគារយើង ដំណើរការការបញ្ជានោះ។

គ. ក្នុងករណីដែលម្ចាស់គណនីរួមណាម្នាក់ ទទួលមរណភាព ឬក្ស័យធន ដែលបណ្ដាលឱ្យប៉ះពាល់ដល់ដំណើរការគណនីបញ្ញើមានកាលកំណត់ លោកអ្នកយល់ព្រមអនុញ្ញាតឱ្យធនាគារយើង៖

១. ព្យួរគណនីរួមរបស់លោកអ្នក និងតម្រូវឱ្យម្ចាស់គណនីរួមដែលនៅសល់ទាំងប៉ុន្មាន អញ្ជើញទៅកាន់សាខាប្រតិបត្តិការណាមួយរបស់ធនាគារយើង ដើម្បីរៀបចំអាណត្តិគណនីឡើងវិញ។ និង/ឬ

២. បិទគណនីបញ្ញើមានកាលកំណត់ តាមឆន្ទានុសិទ្ធិរបស់ធនាគារយើង ឬតាមសំណើរបស់ម្ចាស់គណនីរួមណាម្នាក់ និងប្រគល់ទឹកប្រាក់ដែលអាចប្រើប្រាស់បានដែលនៅសល់ក្នុងគណនីរួម ទៅកាន់ម្ចាស់គណនីរួមដែលនៅសល់។

## ២. សិទ្ធិ និងការទទួលខុសត្រូវរបស់លោកអ្នក

២.១. លោកអ្នកអាច៖

ក. បើកគណនីបញ្ញើមានកាលកំណត់ច្រើនជាងមួយ ទៅតាមការអនុម័តរបស់ធនាគារយើង

ខ. ទទួលបាននូវវិញ្ញាបនបត្រនៃគណនីបញ្ញើមានកាលកំណត់ច្បាប់ដើម សម្រាប់គណនីបញ្ញើមានកាលកំណត់សម្រាប់បុគ្គលឬអាជីវកម្ម ដែលចេញជូនដោយធនាគារយើង។ សម្រាប់គណនីបញ្ញើមានកាលកំណត់សម្រាប់បុគ្គលឬអាជីវកម្ម ដែលត្រូវបានបើកតាមរយៈបណ្ដាញឌីជីថលលោកអ្នកត្រូវអញ្ជើញទៅកាន់សាខាប្រតិបត្តិការណាមួយរបស់ធនាគារយើង ដើម្បីទទួលបានវិញ្ញាបនបត្រនេះ។

២.២. លោកអ្នកយល់ព្រម៖

ក. ផ្ដល់ឯកសារ និងព័ត៌មាន ដែលត្រូវបានតម្រូវដោយធនាគារយើង នៅគ្រប់ពេល និងក្នុងរយៈពេលជាក់លាក់ដែលបានកំណត់ដោយធនាគារយើង។ ក្នុងករណីមានការផ្លាស់ប្ដូរព័ត៌មានដែលបានផ្ដល់ជូនធនាគារយើង លោកអ្នកត្រូវជូនដំណឹងមកកាន់ធនាគារយើង ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

ខ. ទូទាត់ប្រាក់ពន្ធដែលអនុវត្ត ដែលពាក់ព័ន្ធនឹងការប្រាក់ ដែលលោកអ្នកទទួលបានពីគណនីបញ្ញើមានកាលកំណត់ ហើយលោកអ្នកយល់ព្រមអនុញ្ញាតឱ្យធនាគារយើង កាត់ទុកចំនួនប្រាក់ពន្ធនោះ សម្រាប់បង់ជូនអាជ្ញាធរមានសមត្ថកិច្ច ដូចដែលត្រូវបានតម្រូវដោយបញ្ញត្តិច្បាប់ជាធរមាន។

គ. ទូទាត់កម្រៃសេវា ជូនធនាគារយើង ក្នុងករណីដែលលោកអ្នកស្នើសុំវិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់សារជាថ្មី។

ឃ. អនុញ្ញាតឱ្យធនាគារយើង កាត់ប្រាក់ចេញពីគណនីបញ្ញើមានកាលកំណត់ និង/ឬគណនីសន្សំ ឬគណនីចរន្តរបស់លោកអ្នក ដើម្បីទូទាត់សងប្រាក់ដែលលោកអ្នកនៅជំពាក់ធនាគារយើង ពាក់ព័ន្ធនឹងគណនីបញ្ញើមានកាលកំណត់របស់លោកអ្នក។

ង. មិនដកប្រាក់ ឬផ្ទេរប្រាក់ ផ្នែកណាមួយ ឬទាំងអស់ ចេញពីគណនីបញ្ញើមានកាលកំណត់របស់អ្នក លើកលែងតែគណនីនេះត្រូវបានបិទ ដោយអនុលោមតាមបញ្ញត្តិនិងលក្ខខណ្ឌនេះ។

ច. មិនប្រើប្រាស់គណនីបញ្ញើមានកាលកំណត់ ជាទ្រព្យធានា ទោះក្នុងទម្រង់ណាមួយក៏ដោយ សម្រាប់ជាប្រយោជន៍របស់តតិយជនណាមួយ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរ ជាមុនពីធនាគារយើង ប្រសិនបើគណនីបញ្ញើមានកាលកំណត់នោះ ត្រូវបានប្រើប្រាស់ជាទ្រព្យធានាសម្រាប់ជាប្រយោជន៍របស់ធនាគារយើងរួចហើយ។

ឆ. គោរពតាមបញ្ញត្តិច្បាប់ជាធរមានទាំងអស់ រួមបញ្ចូលនិងមិនកម្រិតត្រឹមតែ បញ្ញត្តិច្បាប់ដែលទាក់ទងនឹង ការលាងសម្អាតប្រាក់ និងការប្រឆាំងនឹងហិរញ្ញប្បទានភេរវកម្ម។

ជ. អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន រួមបញ្ចូលតែមិនកម្រិតត្រឹមបទប្បញ្ញត្តិទាក់ទងនឹងការប្រយុទ្ធប្រឆាំងការលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

ឈ. មិនប្រើប្រាស់គណនីបញ្ញើមានកាលកំណត់ សម្រាប់គោលបំណងណាមួយ ដែលមិនស្របច្បាប់ ឬមិនត្រូវបានអនុញ្ញាត ដោយជាក់ច្បាស់ ឬដោយស្ងាត់ស្ងៀម ដោយបញ្ញត្តិនិងលក្ខខណ្ឌនេះ ឬដោយបញ្ញត្តិជាច្បាប់ជាធរមាន ។

ញ. ធ្វើសកម្មភាពដោយសុចរិត លើរាល់ប្រតិបត្តិការ ឬការបញ្ជា ដែលទាក់ទងនឹងគណនីបញ្ញើមានកាលកំណត់របស់លោកអ្នក។ និង

ដ. សហការយ៉ាងពេញទំហឹងជាមួយធនាគារយើង ដូចដែលបានតម្រូវដោយសមហេតុផលរបស់ធនាគារយើង ទាក់ទងនឹងគណនីបញ្ញើមានកាលកំណត់របស់អ្នក។

## ៣. ការព្យួរ ការបង្កក និងការបិទគណនី

៣.១. លោកអ្នកយល់ព្រមអនុញ្ញាតឱ្យធនាគារយើង ព្យួរ បង្ខាំង បង្កក បញ្ចប់ ឬបិទគណនីបញ្ញើមានកាលកំណត់របស់លោកអ្នក ក្នុងករណី៖

ក. មានការឆបោក (មិនថាបានប្រព្រឹត្តដោយលោកអ្នកម្នាក់ឯង ឬរួមជាមួយបុគ្គលដទៃ)។

ខ. លោកអ្នកខកខានក្នុងការផ្តល់ព័ត៌មានពិត ត្រឹមត្រូវ មានសុពលភាព និងគ្មានវិការៈ នៅពេលបើកគណនីបញ្ញើមានកាលកំណត់ ឬនៅពេលបន្ទាប់ដូចដែលបានតម្រូវដោយធនាគារយើង ឬខកខានក្នុងការជូនដំណឹងមកកាន់ធនាគារយើង អំពីការផ្លាស់ប្តូរ ព័ត៌មាន ឬឯកសារ ដែលលោកអ្នកបានផ្តល់ជូនធនាគារយើង។

គ. លោកអ្នកលែងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបានតម្រូវ សម្រាប់ការបើកគណនីនោះ។

ឃ. លោកអ្នកបំពានបញ្ញត្តិ និងលក្ខខណ្ឌនេះ។

ង. លោកអ្នកខកខានក្នុងការសហការដោយសមហេតុផល ជាមួយធនាគារយើង។

ច. លេខទូរស័ព្ទរបស់លោកអ្នក ដែលបានចុះបញ្ជីជាមួយធនាគារយើង មិនអាចទាក់ទងបានសម្រាប់គោលបំណងនៃការផ្ទៀងផ្ទាត់ ឬត្រូវបានប្រើប្រាស់ដោយបុគ្គលដទៃ។

ឆ. លោកអ្នកខកខានក្នុងការបង្ហាញវត្តមាននៅសាខាប្រតិបត្តិការរបស់ធនាគារយើង ក្នុងអំឡុងពេលជាក់លាក់មួយដែលបានកំណត់ដោយធនាគារយើង ក្នុងការអនុវត្តសកម្មភាពណាមួយ ដែលត្រូវបានតម្រូវដោយសមហេតុផលដោយធនាគារយើង។

ជ. ធនាគារយើង ត្រូវបានតម្រូវឱ្យប្រតិបត្តិតាម និយ័តករ ដីការបស់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចឯទៀត និង/ឬគោលនយោបាយ នីតិវិធីអនុវត្ត និងគោលការណ៍ណែនាំប្រតិបត្តិផ្ទៃក្នុងរបស់ធនាគារយើង។

## ៤. ការបង្ហាញព័ត៌មានសម្ងាត់

៤.១. ធនាគារយើង នឹងរក្សាព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក គណនីបញ្ញើមានកាលកំណត់ និងព័ត៌មានដែលពាក់ព័ន្ធឯទៀត ជាការសម្ងាត់។ ប៉ុន្តែ លោកអ្នកយល់ព្រមអនុញ្ញាត ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចដកហូតវិញបាន ឱ្យធនាគារយើងបង្ហាញព័ត៌មានសម្ងាត់ទាំងនោះ៖

ក. ទៅកាន់ ការិយាល័យ សាខា បុត្រសម្ព័ន្ធ បុគ្គលិក ឬភ្នាក់ងាររបស់ ធនាគារ ព្រីនស៍។

ខ. ទៅកាន់ អ្នកផ្តល់សេវាតតិយភាគី ធនាគារទំនាក់ទំនង អ្នកដំណើរការតតិយភាគី ដៃគូអាជីវកម្ម ក្រុមហ៊ុនឬភ្នាក់ងារធានារ៉ាប់រងដែលពាក់ព័ន្ធ សវនករ ទីប្រឹក្សាដែលមានវិជ្ជាជីវៈរបស់ ធនាគារ ព្រីនស៍ ដែលជាប់កាតព្វកិច្ចរក្សាការសម្ងាត់ជាមួយធនាគារយើង។

គ. ទៅកាន់ អាជ្ញាធរដែលពាក់ព័ន្ធ រួមបញ្ចូលទាំង និយ័តករ និងអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធដទៃទៀត។

ឃ. ទៅកាន់បុគ្គលណាមួយ នៅពេលត្រូវបានតម្រូវ ដោយដីកាតុលាការដែលចេញដោយយុត្តាធិការណាមួយ ឬដោយអនុលោមតាមច្បាប់និងបញ្ញត្តិជាធរមាន។

ង. ទៅកាន់ អាជ្ញាធរក្នុងស្រុក ឬក្រៅស្រុក ដែលមានកិច្ចព្រមព្រៀង ឬការរៀបចំជាមួយ ធនាគារ ព្រីនស៍ ដែលតម្រូវឱ្យបង្ហាញព័ត៌មានសម្ងាត់។

ច. ដើម្បីផ្ទៀងផ្ទាត់ និងអនុវត្តសិទ្ធិក្នុងកិច្ចសន្យា និងគោលនយោបាយដែលមានជាធរមានដទៃទៀត។ និង/ឬ

ឆ. ដើម្បីស្វែងរក និងការពារប្រឆាំងនឹងការក្លែងបន្លំ ឬភាពងាយរងគ្រោះនៃបច្ចេកទេស និងសុវត្ថិភាព។

## ៥. ការដោះស្រាយបណ្តឹងអតិថិជន

៥.១. ប្រសិនបើលោកអ្នកមានការបារម្ភ បណ្តឹង យោបល់ ឬត្រូវការការពន្យល់បន្ថែម ទាក់ទងនឹងគណនីបញ្ញើមានកាលកំណត់ ឬបញ្ញត្តិនិងលក្ខខណ្ឌនេះ លោកអ្នកអាចទាក់ទងទៅកាន់សេវាអតិថិជនរបស់ធនាគារយើង តាមរយៈទូរស័ព្ទលេខ៖ ១៨០០ ២០ ៨៨៨៨ ឬអាសយដ្ឋានអេឡិចត្រូនិករបស់ធនាគារ ព្រីនស៍៖ info@princebank.com.kh ឬគេហទំព័រផ្លូវការរបស់ធនាគារយើង។ លោកអ្នកអាចត្រូវបានតម្រូវឱ្យផ្តល់ព័ត៌មានដែលពាក់ព័ន្ធ រួមជាមួយឯកសារគាំទ្រទាំងអស់ ជូនធនាគារយើង នៅពេលលោកអ្នកមានបំណងដាក់ពាក្យបណ្តឹងមកកាន់ធនាគារយើង។

៥.២. ទោះបីពាក្យបណ្តឹងត្រូវបានដាក់ជូនធនាគារ ដោយលោកអ្នក ឬប្រឆាំងនឹងលោកអ្នក ក៏ដោយ លោកអ្នកយល់ព្រមសហការយ៉ាងពេញលេញជាមួយធនាគារយើង ក្នុងការដោះស្រាយបណ្តឹងឬវិវាទ ដូចដែលបានតម្រូវដោយសមហេតុសមផលដោយធនាគារយើង រួមបញ្ចូលដោយមិនកម្រិតត្រឹមតែការបង្ហាញវត្តមានផ្ទាល់របស់លោកអ្នកនៅសាខាប្រតិបត្តិការណាមួយរបស់ធនាគារយើង ក្នុងអំឡុងពេលដែលបានកំណត់ និងជូនដំណឹងទៅកាន់លោកអ្នក និងការផ្តល់ព័ត៌មានឬឯកសារណាមួយ

តាមការស្នើសុំដែលសមហេតុផលរបស់ធនាគារយើង បើមិនដូច្នោះទេ ត្រូវចាត់ទុកថា លោកអ្នកយល់ព្រមទទួលយក ការដោះស្រាយបណ្តឹងឬវិវាទ ដែលធនាគារយើងបានដោះស្រាយ ដោយអនុលោមតាមគោលនយោបាយ នីតិវិធីអនុវត្ត និងគោលការណ៍ណែនាំប្រតិបត្តិដែលមានជាធរមានរបស់ធនាគារយើង។

៦. **សំណងការខូចខាត៖** លោកអ្នកយល់ព្រមការពារ និងសងសំណងការខូចខាត ជូនដល់ធនាគារយើង រួមបញ្ចូលទាំង ម្ចាស់ភាគហ៊ុន អភិបាល និងបុគ្គលិករបស់ធនាគារយើង នូវរាល់ការខាតបង់ ការទាមទារ សកម្មភាព ពាក្យបណ្តឹងណាមួយ ការខូចខាតដោយផ្ទាល់ឬដោយប្រយោល សោហ៊ុយ កម្រៃសេវាផ្លូវច្បាប់ និងការចំណាយ ដែលកើតឡើងចេញពី ឬទាក់ទងនឹង គណនីបញ្ញើមានកាលកំណត់របស់លោកអ្នក។

៧. **ការធ្វើវិសោធនកម្ម៖** លោកអ្នក យល់ព្រមអនុញ្ញាតឱ្យធនាគារយើង ធ្វើវិសោធនកម្មលើបញ្ញត្តិណាមួយនៃបញ្ញត្តិនិងលក្ខខណ្ឌនេះ នាពេលណាមួយ ដោយធ្វើការជូនដំណឹង (តាមវិធីដែលអាចអនុវត្តបាន)ទៅកាន់លោកអ្នក តាមរយៈមធ្យោបាយទំនាក់ទំនងដែលមានរបស់ធនាគារយើង។ លោកអ្នកយល់ព្រមឱ្យធនាគារយើងបិទគណនីបញ្ញើមានកាលកំណត់របស់លោកអ្នក ដោយអនុលោមតាមគោលនយោបាយ នីតិវិធីអនុវត្ត និងគោលការណ៍ណែនាំប្រតិបត្តិដែលមានជាធរមានរបស់ធនាគារយើង និងដោយអនុលោមតាមបញ្ញត្តិនិងលក្ខខណ្ឌនេះ នៅក្នុងករណីដែលលោកអ្នកមិនយល់ព្រមទទួលយកវិសោធនកម្មដែលធនាគារយើងបានជូនដំណឹងទៅកាន់លោកអ្នក។ លោកអ្នកយល់ព្រមថា ប្រសិនបើលោកអ្នកបន្តរក្សាគណនីបញ្ញើមានកាលកំណត់ជាមួយធនាគារយើង បន្ទាប់ពីធនាគារយើង បានផ្តល់ការជូនដំណឹងអំពីវិសោធនកម្មនោះ លោកអ្នកយល់ព្រមទទួលយកវិសោធនកម្មនោះ និងយល់ព្រមគោរពអនុវត្តតាមបញ្ញត្តិនិងលក្ខខណ្ឌដូចដែលបានធ្វើវិសោធនកម្ម។

៨. **ច្បាប់គ្រប់គ្រង និងការដោះស្រាយវិវាទ៖** បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវគ្រប់គ្រងដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ រាល់វិវាទដែលកើតមានឡើង ទាក់ទងនឹងគណនីបញ្ញើមានកាលកំណត់ និងបញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវដោះស្រាយតាមរយៈតុលាការមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា។